**ជម្ងឺ Allergies ខ្លះអាចមានក្នុងមួយឆ្នាំៗរហូតតែម្តង** (Some Allergies Are Year-Round) What's triggering your symptoms?
WUML date-3/19/06

ដោយសារពេលឥឡូវនេះ ជិតដល់រដូវរំហើយ ឬ Spring លោកអ្នកប្រហែលជាយល់ថា វាជិតដល់ពេលមាន allergy ទៀតហើយ។

ប៉ុន្តែ តាម វិជាស្ថានជាតិនៃសហរដ្ឋផ្នែក Allergy និងជម្ងឺឆ្លងដទៃទៀត U.S. National Institute of Allergy and Infectious Diseases បានឲ្យដឹងថា អ្នកដែលធ្លាប់មានជម្ងឺ Allergy នេះ គឺមានពេញមួយឆ្នាំតែម្តង។

អាការ;រោគនៃ Allergy អាចមានជាបណ្តោះអាសន្ន មួយដងមួយកាល ដូចជានៅពេលដែលលោកអ្នកចូលក្នុងផ្ទះមិត្តភក្រ្តដែលមានចញ្ចឹមឆ្មាជាដើម។

ឬលោកអ្នកអាចមាន Allergy ឬទាស់ នឹងរបស់អ្វីមួយ ដែលលោកអ្នកធ្លាប់មានជាញឹកញាប់ ដូចជា លម្អងធូលីនៅក្នុងកំរាលព្រំជាដើម។

ទោះបីជា អ្វីមួយដែលធ្វើឲ្យលោកអ្នកកណ្តាស ឬរមាស់ភ្នែកក៏ដោយ ក៏មធ្យោបាយតែមួយដែលអាចកុំឲ្យលោកអ្នក Allergy បាន គឺជៀសវាង កុំឲ្យប៉ះពាល់ឬនៅជិតរបស់ទាំងនោះតែម្តង បើអាចធ្វើទៅបាន។

ប្រសិនបើ ជៀងវាងពុំបានទេ ថ្នាំ Antihistamines ឬ decongestants ដែលមានលក់នៅតាម pharmacy ក៏អាចជួយសំរាលទប់ទល់បានខ្លះដែរ។ ប៉ុន្តែ ប្រសិនបើវា ពុំមានប្រសិទ្ធភាពទេ លោកអ្នក ប្រហែលជាត្រូវការទៅជួបជាមួយគ្រូពេទ្យខាង ជម្ងឺ Allergy ឬជម្ងឺទាស់ (Allergist) ដើម្បីទទួលការព្យាបាល។

htt://www.healthfinder.gov/news/newsstory.asp?Docid=531321,